# ការវិភាគពីរដ្ឋកម្ពុជាក្នុងលក្ខណៈជារដ្ឋជំរុញអភិវឌ្ឍន៍[1]

តើប្រទេសកម្ពុជាបច្ចុប្បន្ន គឺជារដ្ឋជំរុញអភិវឌ្ឍន៍មែនឬទេ? នេះជាសំនួរមួយធំធេង ដែលត្រូវទទួលការបំភ្លឺពីកម្មវិធីស្រាវជ្រាវមួយមានរយៈពេល ២ឆ្នាំ ។ ជិតពីរទសវត្សរ៍ក្រោយការបញ្ចប់សង្គ្រាមស៊ីវិល[2] និងក្រោយពេលកសាងបានឡើងវិញនូវស្ថិរភាព សណ្ដាប់ធ្នាប់សង្គម និងកំណើនសេដ្ឋកិច្ចខ្ពស់គួរឱ្យកត់សម្គាល់ រដ្ឋាភិបាលកម្ពុជា បានប្រកាសខ្លួនឯងថាជា រដ្ឋជំរុញអភិវឌ្ឍន៍ (ផ្នែកសេដ្ឋកិច្ច) ។ ប៉ុន្ដែមានមតិជំទាស់មួយចំនួនថា រដ្ឋនៅទន់ខ្សោយនៅឡើយ មានដំណើរការមិនទាន់រៀបរយ និងមានលក្ខណៈជាប្រព័ន្ធខ្សែខ្នង (Öjendal and Lilja 2009; Hughes and Un, forthcoming; Pak *et la.* 2007; Kim, forthcoming) ។ កន្លងមក មានការសិក្សាជាច្រើនដែលបានបកស្រាយដោយចោះៗពីលក្ខណៈដូចខាងលើ ប៉ុន្ដែនៅមិនទាន់មានការសិក្សាណាមួយដែលផ្ដោតចំលើប្រទេសកម្ពុជាក្នុងលក្ខណៈជារដ្ឋជំរុញអភិវឌ្ឍន៍នោះទេ ។

**តើរដ្ឋកម្ពុជា នឹងចាប់យកមាគ៌ាអភិវឌ្ឍន៍ពិតប្រាកដ ឬក៏ផ្លូវផ្សេង ជាពិសេសនៅចំពោះមុខប្រាក់ចំណូលដ៏ច្រើនសន្ធឹកសន្ធាប់ពីធនធានរ៉ែ និងប្រេងកាត ដែលទំនងនឹងទទួលបាននាពេលឆាប់ៗ ?**

ចាប់ពីដើមទសវត្សរ៍១៩៨០ ដល់ដើមទសវត្សរ៍១៩៩០ អ្នកនិយមរបបសេរីបែបថ្មី បានជំរុញជំដែករើកញ្ជែកឱ្យមានការកាត់បន្ថយតួនាទីរបស់រដ្ឋ និងការដើរតាមកំលាំងទីផ្សារ (Thorbecke 2007; Fukuyama 2004) ។ ប៉ុន្ដែបរាជ័យ និងកំហិតកំណត់នៃឯកជនភាវូបនីយកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ កង្វះសមត្ថភាព និងដែនឥទ្ធិពលតូចរបស់រដ្ឋ (អន្ដរាគមន៍ និងលទ្ធភាពលូកដៃចូលទីផ្សារ) ដើម្បីជួយទ្រទ្រង់ទីផ្សារ មិនបានជួយជំរុញឱ្យមាន កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌ឡើយ ។ លំនាំគំនិតថ្មីដែលផ្ដល់សារៈសំខាន់ និងភាពចាំបាច់ដល់សមត្ថភាពរបស់រដ្ឋ និងគុណភាពស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច បានរីកលូតលាស់កាន់តែខ្លាំង ចាប់ពីដើមទសវត្សរ៍១៩៩០ (Fukuyama 2004) ។ លំនាំគំនិតថ្មីនេះ វាសមស្របល្អ នៅពេលមានកង្វះអន្ដរាគមន៍ពីរដ្ឋ (បទបញ្ញត្តិគ្រប់គ្រងទីផ្សារ និងការពង្រឹងអនុវត្ត) ដូចក្នុងករណីសហរដ្ឋអាមេរិកដែលត្រូវគេបន្ទោសថា ជាដើមហេតុនៃការផ្ទុះវិបត្តិសេដ្ឋកិច្ចសាកលលោកនាពេលថ្មីៗ ។ ជាប្រតិកម្មក្នុងរឿងនេះ គេឃើញមានសំណើឱ្យបំផុសឡើងវិញនូវអន្ដរាគមន៍របស់រដ្ឋក្នុងសេដ្ឋកិច្ច ទាំងសម្រាប់រដ្ឋាភិបាលដែលប្រកាន់ជំហរបណ្ដោយតាមកំលាំងទីផ្សារ ដូចនៅសហរដ្ឋអាមេរិកក្ដី ។ ដូចគ្នាដែរ ចម្លើយតបយ៉ាងស័ក្ដិសិទ្ធិរបស់រដ្ឋាភិបាលចិនចំពោះវិបត្តិនេះ បានបញ្ជាក់គាំទ្រពីប្រសិទ្ធភាពគំរូអភិវឌ្ឍន៍ដឹកនាំដោយរដ្ឋសម្រាប់ដោះស្រាយការរីករាវផ្នែកហិរញ្ញវត្ថុ ដោយរក្សាបាននូវកំណើនសេដ្ឋកិច្ច ។ ដូច្នេះ ដល់ពេលវេលាដែល ត្រូវរើសយកមកប្រើសាជាថ្មីនូវគោលគំនិត "ឱ្យរដ្ឋចូលមកពាក់ព័ន្ធវិញ" (Skocpol 1985) ។

ដោយទទួលស្គាល់ពីភាពចាំបាច់ និងប្រសិទ្ធភាពនៃការអភិវឌ្ឍដែលដឹកនាំដោយរដ្ឋនោះ អង្គភាពចំនួនបីនៅ CDRI គឺមានផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងផ្នែកភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ បានរួមគ្នាផ្ដួចផ្ដើមគំនិតបង្កើតកម្មវិធីស្រាវជ្រាវនេះឡើង ដើម្បីស្វែងយល់ពីរដ្ឋកម្ពុជា ។

កម្មវិធីស្រាវជ្រាវនេះ មានគោលដៅចំបងពិនិត្យពីលក្ខណៈនៃរដ្ឋកម្ពុជាទាំងក្នុងទស្សនវិស័យបែបប្រៀបធៀប និងបែបប្រវត្តិសាស្ត្រ ដោយធ្វើការពិចារណាលើគំរូខុសៗគ្នានៃរដ្ឋដូចមានបង្ហាញនៅខាងក្រោម ដើម្បីចូលរួមចំណែកដល់ការសិក្សាបែបទ្រឹស្ដីអំពីរដ្ឋកម្ពុជា ។ ដោយឡែក ការសិក្សាព្យាយាមឆ្លើយនឹងសំនួរសំខាន់ៗមួយចំនួនដូចជា: តើរដ្ឋកម្ពុជាមានប្រសិទ្ធភាពប៉ុណ្ណាក្នុងក្របខ័ណ្ឌជារដ្ឋជំរុញអភិវឌ្ឍន៍? ទាក់ទិននឹងសមត្ថភាពរដ្ឋ តើរដ្ឋមានចំណុចខ្លាំងអ្វីខ្លះ? តើរដ្ឋកម្ពុជា មានស្វ័យភាពប៉ុណ្ណាពាក់ព័ន្ធនឹងវណ្ណៈផ្សេងៗក្នុងសង្គម (វណ្ណៈគ្រប់គ្រង)? តើរដ្ឋលូកដៃចូលក្នុងសេដ្ឋកិច្ចបានកម្រិតណា?

## ហេតុផលត្រូវធ្វើការស្រាវជ្រាវ

Hughes and Un (បោះពុម្ពផ្សាយក្នុងពេលខាងមុខ) អះអាងថា ប្រទេសកម្ពុជា បានងើបផុតពីសម័យក្រោយជម្លោះ និងឈានចូលទៅក្នុងដំណាក់កាលថ្មីនៃការផ្លាស់ប្ដូរសេដ្ឋកិច្ច ។ ការសិក្សានេះ មានគោលដៅពិនិត្យឱ្យបានឆ្ងាយជាងការសិក្សារបស់ Hughes and Un ដោយចង់បង្ហាញយ៉ាងពិស្ដារពីចរិតលក្ខណៈជាមូលដ្ឋាននៃរដ្ឋកម្ពុជា និងប្រមើលមើលពីទិសដៅដែលរដ្ឋកំពុងឈានទៅរក គឺថា តើរដ្ឋកម្ពុជា នឹងចាប់យកមាគ៌ាអភិវឌ្ឍន៍

---

១ ដោយលោក អ៊ូ ស៊ីវហួច លោក លន់ ពិដេ លោក ឃៀង សុធី និងកញ្ញា អ៊ូច ច័ន្ទតារ៉ានី (អ្នកស្រាវជ្រាវ នៃ CDRI) ដោយមានការជួយណែនាំ និងត្រួតពិនិត្យពីលោក គីម សេតារា (អ្នកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI) និងបណ្ឌិត អ៊ុន ឃាង (ជំនួយការសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Northern Illinois) ។ អត្ថបទនេះជាសេចក្ដីសង្ខេបនៃឯកសារគោលគំនិតសម្រាប់កម្មវិធីរដ្ឋជំរុញអភិវឌ្ឍន៍ ដែលបានចាប់ផ្ដើមឡើងពីត្រីមាសទី៤ ឆ្នាំ២០០៩ និងគ្រោងបញ្ចប់នៅពាក់កណ្ដាលឆ្នាំ២០១១ ។ ឯកសារនេះ មានគោលដៅចំបងណែនាំកម្មវិធីនេះដល់បុគ្គលគោលដៅ ដូចជា អ្នកកសាងគោលនយោបាយ សហគមន៍ផ្ដល់ជំនួយ អ្នកសិក្សា និងក្រុមសង្គម ស៊ីវិល ព្រមទាំងវិស័យឯកជន ។

២ សង្គ្រាមស៊ីវិល បានបញ្ចប់អស់នៅក្នុងឆ្នាំ១៩៩៨ នៅពេលដែលភាគីខ្មែរក្រហម បានធ្វើសមាហរណកម្មពេញលេញជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ។

ពិតប្រាកដ ឬក៏ផ្លូវផ្សេង ជាពិសេសនៅចំពោះមុខប្រាក់ចំណូលដ៏ច្រើនសន្ធឹកសន្ធាប់ពីធនធានរ៉ែ និងប្រេងកាត ដែលទំនងនឹងទទួលបាននាពេលឆាប់ៗ ។ តាមការពិនិត្យឃើញជាក់ស្តែងកន្លងមក អ្នកកសាងគោលនយោបាយរបស់រដ្ឋាភិបាល អ្នកផ្តល់ជំនួយ ពាណិជ្ជករថ្នាក់ខ្ពស់ តួអង្គសង្គមស៊ីវិល និងសូម្បីតែអ្នកសិក្សាទៀតសោត ក៏ខ្វះខាតការយល់ដឹងពីលទ្ធផលការស្រាវជ្រាវដ៏សំខាន់ៗទាំងនេះដែរ ។ ការសិក្សានេះ នឹងជួយបំពេញចន្លោះខ្វះខាតទាំងនេះ ទាំងផ្នែកទ្រឹស្តី និងការអនុវត្ត ។ ជាងនេះទៅទៀត ការសិក្សានឹងបង្ហាញថា តើបុគ្គលណាត្រូវធ្វើអ្វីខ្លះ ដើម្បីធានាឱ្យកម្ពុជាអាចចាប់យកមាគ៌ាអភិវឌ្ឍន៍ដ៏ត្រឹមត្រូវ ។ យើងក៏មានបំណងពិនិត្យមើលលើបទពិសោធន៍អភិវឌ្ឍន៍នៃប្រទេសផ្សេងៗ និងជ្រើសរើសមេរៀនល្អៗដែលសមស្របសម្រាប់បរិបទកម្ពុជា ។

## ការធ្វើផែនការស្រាវជ្រាវ

ដើម្បីសម្រេចបានតាមកម្មវត្ថុនៃកម្មវិធីខាងលើ យើងបានរៀបចំការសិក្សានេះជាបីដំណាក់កាលៈ

- ការវិភាគពីរដ្ឋកម្ពុជាៈ តើជារដ្ឋជំរុញអភិវឌ្ឍន៍ មែនឬទេ?
- រដ្ឋ និងការយកពន្ធនៅកម្ពុជា
- រដ្ឋ និងគោលនយោបាយកសិកម្មនៅកម្ពុជា

គម្រោងទី១ នឹងវិភាគពីចរិតលក្ខណៈនៃរដ្ឋកម្ពុជាដោយប្រើប្រភេទផ្សេងៗផ្អែកតាមទ្រឹស្តីនៃរដ្ឋ ដូចមានបង្ហាញនៅខាងក្រោម ។ គម្រោងនេះ ក៏នឹងពិនិត្យពីសមាសធាតុសំខាន់ៗ ដូចជា សមត្ថភាព ស្វ័យភាព និងដែនឥទ្ធិពលរបស់រដ្ឋ ។ គម្រោងពីរទៀត គឺជាករណីសិក្សាជាក់ស្តែងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់រដ្ឋ ។ គម្រោងនីមួយៗនឹងបញ្ចប់ ដោយមានការបោះពុម្ពផ្សាយជាឯកសារពិភាក្សាដោយវិទ្យាស្ថាន CDRI ។ ដើម្បីជំរុញឥទ្ធិពល និងការផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ យើងនឹងប្រឹងប្រែងកសាងជាឯកសារខ្លីៗសម្រាប់ចុះផ្សាយនៅក្នុងព្រឹត្តបត្រ និងសៀវភៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ។

ផ្នែកបន្ទាប់ នឹងរៀបរាប់លំអិតថែមទៀតពីប្រវត្តិនៃការសិក្សា និងពិភាក្សាពីប្រភេទខុសៗគ្នានៃគំរូរដ្ឋដែលនឹងត្រូវយកមកប្រើ ដើម្បីអង្កេតលើចរិតលក្ខណៈនៃរដ្ឋកម្ពុជា ។ ការសិក្សានេះ ក៏បង្ហាញនូវការកែកញ្ចែកមួយចំនួនអំពីទំនាក់ទំនងជិតស្និទ្ធរវាងសមត្ថភាពរដ្ឋ ហើយនិងចំណូលពន្ធ និងគោលនយោបាយកសិកម្ម ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា ប្រទេសកម្ពុជា ។ សេចក្តីសង្ខេបនេះ នឹងត្រូវប្រើប្រាស់ជាក្របខ័ណ្ឌសម្រាប់ការស្រាវជ្រាវ ។

## ការសិក្សាឯកសារអំពីគំរូរដ្ឋផ្សេងៗ និងភាពជាប់ទាក់ទងល្អសម្រាប់ការសិក្សាពីរដ្ឋកម្ពុជា

ដោយផ្តោតការពិភាក្សាទៅលើរដ្ឋ ឯកសារផ្សេងៗជាច្រើន បានបង្ហាញពីគំរូរដ្ឋខុសៗគ្នា ដែលគេប្រើប្រាស់សម្រាប់ធ្វើវិភាគ ។ ឯកសារ Evans (1989), Evans (1995) និង Hutchcroft (1998) បានបង្កើតជាខ្សែបន្ទាត់មួយ ដែលនៅលើនោះ គាត់បានដាក់តំរៀបគ្នានូវគំរូរដ្ឋផ្សេងៗ ចាប់ពីរដ្ឋមានឥទ្ធិពលខ្លាំងបំផុត ហៅថារដ្ឋជំរុញអភិវឌ្ឍន៍ (developmental state) រហូតដល់រដ្ឋមានប្រសិទ្ធភាពតិចបំផុត ហៅថារដ្ឋជីវិតគេ (predatory state) ហើយនៅចន្លោះរដ្ឋទាំងពីរនេះ មានរដ្ឋច្រើនបែបទៀត ដូចជា រដ្ឋមូលធនបក្សពួកនិយម (crony capitalist state) រដ្ឋមូលធនការិយាធិបតេយ្យ (bureaucratic capitalist state) និងរដ្ឋជ័យភ័ណ្ឌ (booty state) ជាដើម ។ លោក Evans (Evans 1989; Evans 1995: 44) បានលើកឡើងថា រដ្ឋជីវិតគេ សំដៅដល់រដ្ឋដែលដកហូតយកយ៉ាងច្រើននូវប្រាក់នៅសល់ដែលអាចធ្វើវិនិយោគបាន និងផ្តល់តិចតួចណាស់នូវទំនិញសមូហភាព ។ Evans (1995: 44) អះអាងថា រដ្ឋ Zaire (បានប្តូរឈ្មោះទៅជាសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ) ស្ទើរតែក្លាយជារដ្ឋជីវិតគេសុទ្ធសាធ (អាចយកជាគំរូនៃរដ្ឋប្រភេទនេះបាន) ដោយក្នុងនេះ មានអ្នកនយោបាយវណ្ណៈខ្ពស់មួយក្រុមតូចដែលគ្រប់គ្រងលើក្បាលម៉ាស៊ីនរដ្ឋ និងដែលប្រឹងគិតគូរតែពីរឿងស្វែងរកប្រាក់កំរៃក្រៅផ្លូវការ និងមានប្រព័ន្ធការិយាធិបតេយ្យគុណភាពអន់មួយដែលបណ្តោយឱ្យមានការលក់ដូរមុខងាររដ្ឋ និងការឃុបឃិតរវាងអ្នកការិយាធិបតេយ្យ អ្នកនយោបាយ និងពួកអាជីវករ ក្នុងការលួចប្លន់ធនធានរដ្ឋ ជាដើម ។ រដ្ឋប្រភេទនេះ ជាឧបសគ្គមួយដល់ការលូតលាស់សេដ្ឋកិច្ច ។

ផ្ទុយទៅវិញ រដ្ឋជំរុញអភិវឌ្ឍន៍ដែលស្ថិតនៅចុងម្ខាងទៀតនៃខ្សែបន្ទាត់ គឺរដ្ឋដែលមានសមត្ថភាពជួយលើកស្ទួយ ជំនាញសហគ្រិនក្នុងរយៈពេលវែង និងសកម្មភាពផ្សេងៗក្នុងវិស័យអាជីវកម្មឯកជន តាមរយៈការផ្តល់គ្រឿងលើកទឹកចិត្តផ្សេងៗ និងជួយការពារវិនិយោគសម្រាប់ការលូតលាស់ ដូចជា នៅកូរ៉េខាងត្បូង តៃវ៉ាន់ និងជប៉ុន ជាដើម (Evans 1989; Donald 1998) ។ រដ្ឋជំរុញអភិវឌ្ឍន៍ ក៏មាន "ស្វ័យភាពបង្កប់" ដែលអាចសំគាល់បាន តាមកិច្ចសហការរវាងវិស័យឯកជន ស្ថាប័នរដ្ឋ និងអ្នកការិយាធិបតេយ្យ ។ ទោះរដ្ឋប្រភេទនេះ មានបង្កប់នូវវិស័យអាជីវកម្មឈានមុខក្តី ក៏ Leftwich (2000: 160–167) បានស្នើឡើងនូវលក្ខណៈសំគាល់មួយចំនួនថែមទៀតសម្រាប់រដ្ឋជំរុញអភិវឌ្ឍន៍ ។ លក្ខណៈទីមួយ ឥស្សរជនអង់អាច ជំរុញអភិវឌ្ឍន៍ដែលស្អាតស្អំគ្រាន់បើ ដូចជា លោក Lee Kuan Yew នៅសិង្ហបុរី និងឧត្តមសេនីយ៍ Park Chung Hee នៅកូរ៉េខាងត្បូង ។ ទីពីរ រដ្ឋដែលមានស្វ័យភាព និងមិនចំណុះឱ្យក្រុមអ្នកមានផលប្រយោជន៍ធំៗ គឺការពារផលប្រយោជន៍ជាតិ ។ ទីបី ក្បាលម៉ាស៊ីនការិយាធិបតេយ្យរឹងមាំដំណើរការដោយមន្ត្រីដែលមានសមត្ថភាពរបស់រដ្ឋ និងដែលដាក់ចេញនូវគោលនយោបាយ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។ លក្ខណៈសំគាល់ផ្សេងៗទៀតមានដូចជា សង្គមស៊ីវិលទន់ខ្សោយដែលនាំឱ្យរដ្ឋមានអំណាចគ្រប់គ្រងបាន

ដើម្បីធានាដល់ការពង្រឹងរបបនយោបាយ, សមត្ថភាពរដ្ឋក្នុងការលើកស្ទួយផលប្រយោជន៍សេដ្ឋកិច្ច (ការប្រមូលផ្ដុំមូលធន), ការអនុវត្តសិទ្ធិមនុស្សនៅខ្សោយ ដូចឃើញមាននៅសិង្ហបុរី និង តៃវ៉ាន់ ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍, ភាពពេញច្បាប់ និងលទ្ធផលល្អ (របបគ្រប់គ្រងនៃរដ្ឋជំរុញអភិវឌ្ឍន៍ មានលក្ខណៈពេញច្បាប់ និងសំរេចបានកំណើនលឿន) ។

Haber (2002: p.12) បានពន្យល់ពីមូលធនបក្សពួកនិយម ថាជាប្រព័ន្ធមួយដែលក្នុងនោះ អ្នកដែលមានចំណងទាក់ទងរឹងមាំជាមួយអ្នកមានវណ្ណៈខ្ពស់ក្នុងរដ្ឋអំណាច តែងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចធំធេង ដូចជាសិទ្ធិពិសេសទទួលបានឥណទានថោកជាងធម្មតាពីធនាគាររដ្ឋ ឬការអនុញ្ញាតឱ្យគិតថ្លៃផលិតផលខ្ពស់ជាងថ្លៃលំនឹងទីផ្សារ ។ ក្រុមបក្សពួកនិយមទាំងនោះបែងចែកកំរៃសេដ្ឋកិច្ចដែលខ្លួនទទួលបានទៅឱ្យគូកនខ្លួនដែលជាអ្នកមានសិទ្ធិអំណាចក្នុងការបង្កើតគោលនយោបាយសេដ្ឋកិច្ច ។ ដូច្នេះ អ្នកមានបុណ្យស័ក្តិក្នុងរដ្ឋអំណាចគ្មានហេតុផលអ្វីនឹងបង្កើតគោលនយោបាយដែលរារាំងដល់ផលប្រយោជនរបស់បក្សពួកខ្លួនទេ ។ Sharafutdinova (2007) លើកថែមទៀតថា មូលធនបក្សពួកនិយមនៅរុស្ស៊ីបានកាត់បន្ថយភាពត្រឹមត្រូវពេញច្បាប់របស់រដ្ឋ ។

Hutchcroft ក៏បានបង្កើតប្រព័ន្ធបែងចែកប្រភេទរដ្ឋមួយ ដែលមានអនុប្រភេទចំនួនពីរ គឺមូលធននិយមការិយាធិបតេយ្យ និងមូលធននិយមជ័យភ័ណ្ឌ ។ ក្នុងអនុប្រភេទទីមួយ "អ្នកមានវណ្ណៈខ្ពស់ក្នុងការិយាធិបតេយ្យដកហូតយកបុព្វសិទ្ធិពីវណ្ណៈអាជីវករទន់ខ្សោយ" រីឯក្នុងអនុប្រភេទទីពីរវិញ "វណ្ណៈអាជីវករដែលមានអំណាចខ្លាំងដកហូតយកបុព្វសិទ្ធិពីប្រព័ន្ធការិយាធិបតេយ្យដែលដំណើរការមិនស៊ីចង្វាក់គ្នា" (Hutchcroft 1998:20) ។ Hutchcroft លើកឡើងថា ប្រទេសថៃ តំណាងឱ្យមូលធននិយមការិយាធិបតេយ្យ ហើយហ្វីលីពីន តំណាងឱ្យមូលធននិយមជ័យភ័ណ្ឌ ។

តាមការសង្កេតរបស់ Moore (2004) នៅក្នុងប្រវត្តិសាស្ត្រ ការផ្លាស់ប្តូរក្លាយជារដ្ឋទំនើបនៃបណ្តាប្រទេសនៅអឺរ៉ុប មិនមែនជំរុញដោយការិយាធិបតេយ្យសមហេតុផល ដូចក្នុងទ្រឹស្តីរបស់ Weber ឬដូចក្នុងគំរូមូលធននិយមរបស់ពួក Marxist នោះទេ ។ ផ្ទុយទៅវិញ បំលាស់ប្តូររដ្ឋដូចរៀបរាប់ខាងលើ សម្រេចបានតាមរយៈការធ្វើអន្តរកាលក្លាយជារដ្ឋពន្ធដារ ដែលក្នុងនោះ ចំណូលរដ្ឋបានមកពីការយកពន្ធ ។ រដ្ឋប្រភេទនេះ មានស្ថាប័នរឹងមាំ មានសមត្ថភាពអនុវត្តគោលនយោបាយអភិវឌ្ឍន៍ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។ រដ្ឋជំរុញអភិវឌ្ឍន៍ទំនើបៗនៅតំបន់អាស៊ីខាងកើត ដូចជា ជប៉ុន តៃវ៉ាន់ និងកូរ៉េខាងត្បូង សុទ្ធតែមានមូលដ្ឋានយកពន្ធរឹងមាំ ។ ផ្ទុយទៅវិញ រដ្ឋមួយចំនួនទៀត ទទួលធនធានហិរញ្ញវត្ថុតាមរយៈការទាញយកធនធានធម្មជាតិក្នុងប្រទេសរបស់ខ្លួន ដូចជា ប្រេងកាត ឬឈើ និង/ឬ តាមរយៈជំនួយពីបរទេស ហើយគេហៅរដ្ឋទាំងនេះថា "រដ្ឋចាយទ្រព្យធន (rentier state)" ។ បណ្តាប្រទេសនៅមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង ដែលទទួលបានប្រាក់ចំណូលភាគច្រើនមកពីការលក់ធនធានធម្មជាតិ គឺស្ថិតក្នុងប្រភេទនេះ ។ តាមការពិនិត្យឃើញជាក់ស្តែង រដ្ឋទាំងនេះ មិនសូវមានការទាមទារគណនេយ្យភាពច្រើនពីសំណាក់ប្រជាពលរដ្ឋទេ (Moore 2004; Ross 2004) ។

អ្នកកសាងគោលនយោបាយ និងអ្នកស្រាវជ្រាវភាគច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គេចាត់ទុកកំណើនសេដ្ឋកិច្ច ជំរុញដោយការនាំចេញ និងផ្អែកលើកម្មន្តសាល ថាជាសមាសធាតុចាំបាច់នៃកំណើនសេដ្ឋកិច្ចឆាប់រហ័ស និងមានចីរភាព ។ តាមបទពិសោធន៍របស់ប្រទេសមួយចំនួននៅអាស៊ី គោលគំនិតបែបនេះ អាចនាំឱ្យមានការមើលរំលងកសិកម្មដែលជាមូលដ្ឋានដ៏សំខាន់នៃការស្ទុះឡើងសេដ្ឋកិច្ច ។ ឧទាហរណ៍ ប្រទេសតៃវ៉ាន់ នៅដំណាក់កាលដំបូងនៃការអភិវឌ្ឍ បានពង្រឹងវិស័យកសិកម្ម តាមរយៈកំណែទម្រង់បំរើគោលដៅនេះ និងអន្តរាគមន៍ផ្សេងៗទៀតរបស់រដ្ឋ ។ ផលចំណេញដែលហូរហៀរចេញពីវិស័យកសិកម្ម មានច្រើនគួរកត់សំគាល់សម្រាប់ការរីកលូតលាស់ឧស្សាហកម្មដែលបន្ទាប់មកត្រូវក្លាយជាកត្តាចំបងនៃកំណើនសេដ្ឋកិច្ច (Amsden 1985: 87–88) ។ ដូចគ្នាដែរ ប្រទេសជប៉ុនក្នុងសម័យ Meiji (1868-1912) បានរីកលូតលាស់គួរឱ្យកត់សំគាល់ ដោយសារមានវិស័យកសិកម្មរឹងមាំ ។ កំណើនខាងកសិកម្ម បានជួយពង្រីកការអភិវឌ្ឍក្នុងវិស័យមិនមែនកសិកម្ម តាមរយៈការផ្ដល់ធាតុចូល ដូចជា វត្ថុធាតុដើមជាដើម ព្រមទាំងការផ្ទេរកំលាំងពលកម្ម និងមូលធន (Akino and Hayami 1974) ។ ដូច្នេះ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសសំបូរធនធាន ដូចជា កម្ពុជាជាដើម ដែលមានប្រជាពលរដ្ឋ ប្រមាណ ៨០% រស់នៅទីជនបទ ដោយប្រកបរបរកសិកម្ម ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ គេត្រូវពឹងផ្អែកជាសំខាន់លើការពង្រឹងវិស័យកសិកម្ម ។

**ផលចំណេញដែលហូរហៀរចេញពីវិស័យកសិកម្ម មានច្រើនគួរកត់សំគាល់សម្រាប់ការរីកលូតលាស់ឧស្សាហកម្មដែលបន្ទាប់មក ត្រូវក្លាយជាកត្តាចំបងនៃកំណើនសេដ្ឋកិច្ច ។**

**កំណើនខាងកសិកម្ម បានជួយពង្រីកការអភិវឌ្ឍក្នុងវិស័យមិនមែនកសិកម្ម តាមរយៈការផ្ដល់ធាតុចូល ដូចជា វត្ថុធាតុដើមជាដើម ព្រមទាំងការផ្ទេរកំលាំងពលកម្ម និងមូលធន ។**

ក្រោយពីបានយល់ដឹងពីគំរូរដ្ឋខុសៗគ្នា គេអាចសង្ស័យថា ប្រទេសនីមួយៗ មិនអាចចាត់ចូលយ៉ាងដាច់ណាត់ទៅក្នុងគំរូណាមួយបានទេ ។ ជាក់ស្តែង សូម្បីតែការអះអាងថា បណ្តាប្រទេស ដូចជា សិង្ហបុរី និងតៃវ៉ាន់ ជាដើម ត្រូវចាត់ចូលក្នុងប្រភេទប្រទេសជំរុញអភិវឌ្ឍន៍ ក៏នៅតែអាចជជែកតវ៉ា

បាននៅឡើយ ។ បើក្រឡេកមើលមកកម្ពុជាវិញ គឺមានឯកសារកាន់តែច្រើន ដែលផ្ដល់ការសន្និដ្ឋានខុសៗគ្នាស្ដីពី លំនាំអភិវឌ្ឍន៍នៅក្នុងប្រទេស ។ សម្រាប់សេដ្ឋកិច្ច កំណើនប្រាក់ចំណូលវិជ្ជមានក្នុងមួយទសវត្សរ៍ចុងក្រោយ ដោយមានអត្រាកំណើនលេខពីរខ្ទង់ក្នុង ៤ឆ្នាំជាប់ៗគ្នាផង (២០០៤-២០០៧) បានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃគោលនយោបាយរបស់រដ្ឋ ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។ កំណើនគួបផ្សំគ្នានៃវិស័យកសិកម្ម ឧស្សាហកម្ម (ជាពិសេសផ្នែកកាត់ដេរ) និងទេសចរណ៍ គឺជាកំលាំងដ៏សំខាន់ជំរុញកំណើនសេដ្ឋកិច្ច ។ នៅចំពោះមុខសមិទ្ធផលដ៏គួរកោតសរសើរនេះ គេមិនគួរមើលរំលងនូវសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការរក្សាសន្តិភាព និងសណ្ដាប់ធ្នាប់សង្គម ដែលជាលក្ខខណ្ឌត្រូវមានជាមុនសម្រាប់ការលូតលាស់សេដ្ឋកិច្ច ។ ទាក់ទិននឹងការពង្រឹងកំលាំងនយោបាយវិញ មានការអះអាងថា សង្គមស៊ីវិលកម្ពុជាដែលទន់ខ្សោយ ត្រូវបានគ្រប់គ្រងដោយរដ្ឋ (Ou *et al*. 2009) គឺហាក់ដូចគ្នានឹងចរិតលក្ខណៈមួយរបស់រដ្ឋជំរុញអភិវឌ្ឍន៍ដទៃទៀត ដូចជា សិង្ហបុរី និងតៃវ៉ាន់ ជាដើម ។

អ្នកស្រាវជ្រាវមួយចំនួនបានជំទាស់នឹងការអះអាងខាងលើនេះ ។Un (2004) and Hughes (2003) បានសន្និដ្ឋានថា កម្ពុជានៅតែត្រូវគេចាត់ទុកជារដ្ឋទន់ខ្សោយ ដែលមានអំពើពុករលួយច្រើនពាសពេញ និងមានរបបនីតិរដ្ឋទន់ខ្សោយ ។Cock (បោះពុម្ពផ្សាយក្នុងពេលខាងមុខ) បានគូសបញ្ជាក់ពីការកើតមានប្រព័ន្ធគ្រប់គ្រងរដ្ឋដោយជនមួយក្រុមតូចដែលឆ្លៀតយកចំណេញពីការទទួលបានបុព្វសិទ្ធិផ្សេងៗក្នុងការប្រើប្រាស់ដីសម្បទាន និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។ គាត់យល់ថា បាតុភូតនេះ ជាឧបសគ្គរាំងស្ទះដល់ការបង្កើតរដ្ឋដែលត្រឹមត្រូវតាមច្បាប់ ។ ស្រដៀងគ្នានេះដែរ Pak and Craig (2008) បានបង្ហាញថា គណនេយ្យភាពរបស់រដ្ឋ វាយរលើបណ្ដាញខ្សែខ្នងភក្ដីភាព និងការស្វែងរកប្រាក់កំរៃក្រៅផ្លូវការ ។ ការសិក្សានេះ ក៏នឹងពិនិត្យពីទស្សនៈរបស់អ្នកស្រាវជ្រាវខុសៗគ្នា ហើយប្រៀបធៀបទស្សនៈទាំងនោះទៅនឹងការពិនិត្យឃើញជាក់ស្ដែង ដើម្បីធ្វើវិភាគពីចរិតលក្ខណៈនៃរដ្ឋកម្ពុជា ។ ចំណុចសំខាន់សម្រាប់ការវិភាគ គឺការយកពន្ធ និង គោលនយោបាយកសិកម្ម ។

សរុបមក ការយល់ដឹងពីគោលគំនិតស្ដីពីរដ្ឋដែលអ្នកស្រាវជ្រាវខុសៗគ្នាបានលើកឡើង មានសារៈសំខាន់បំផុត ដើម្បីក្ដាប់បានពីចរិតលក្ខណៈនៃរដ្ឋកម្ពុជា ដែលជាគោលដៅចំបងនៃកម្មវិធីស្រាវជ្រាវនេះ ។ ក្របខ័ណ្ឌនៃការវិភាគក្នុងការសិក្សា គឺការស្វែងយល់ពីចរិតលក្ខណៈសំខាន់ៗរបស់រដ្ឋជំរុញអភិវឌ្ឍន៍ ដើម្បីយកមកពិចារណាលើព័ត៌មានជាក់ស្ដែងដែលទទួលបានលើរដ្ឋកម្ពុជា ។

## វិធីសាស្ត្រស្រាវជ្រាវ

ស្របតាមក្របខ័ណ្ឌនៃការស្រាវជ្រាវ ជាដំបូង ក្រុមស្រាវជ្រាវនឹងចំណាយពេលយ៉ាងច្រើន ពិនិត្យឡើងវិញលើការសិក្សាប្រៀបធៀបថ្នាក់តំបន់ និងអន្តរជាតិ ស្ដីពីរដ្ឋ និងមុខងាររដ្ឋ ការបង្កើតនិងកសាងរដ្ឋ ប្រភេទផ្សេងៗនៃរដ្ឋ ចរិតលក្ខណៈនៃរដ្ឋភាគខាងជើងនិងរដ្ឋភាគខាងត្បូង រចនាសម្ព័ន្ធរដ្ឋ ស្វ័យភាពនិងដែនឥទ្ធិពល ការិយាធិបតេយ្យរបស់រដ្ឋនិងស្ថាប័នក្រៅផ្លូវការ (បណ្ដាញខ្សែខ្នងបែបថ្មី) អាណានិគមនិយម ការយកពន្ធ ការបង្កើតនិងអនុវត្តគោលនយោបាយរដ្ឋ ចំណុចខ្សោយនិងចំណុចខ្លាំងរបស់រដ្ឋ ទំនាក់ទំនងរវាងជនឋានៈខ្ពស់ក្នុងរដ្ឋនិងវណ្ណៈគ្រប់គ្រង ទំនាក់ទំនងរវាងរដ្ឋនឹងអ្នកផ្ដល់ជំនួយ/តួអង្គអន្តរជាតិ ជាពិសេសប្រទេសចិនដែលជាមហាអំណាចក្នុងតំបន់ ។ ការពិនិត្យឡើងវិញនេះ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការស្វែងយល់និងវិភាគពីរដ្ឋកម្ពុជា ។ ក្នុងគោលដៅដូចគ្នា ក៏នឹងមានការពិនិត្យមើលនូវការសិក្សាជាប់ពាក់ព័ន្ធ ព្រមទាំងគោលនយោបាយ ច្បាប់ និងបទបញ្ញត្តិនានារបស់កម្ពុជា ។

នៅដំណាក់កាលបន្ទាប់ ការសិក្សា នឹងផ្ដោតទៅលើបទសម្ភាសន៍ស៊ីជំរៅជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ ជាអាទិ៍ អ្នកកសាងគោលនយោបាយ ពាណិជ្ជករធំៗ អ្នកដឹកនាំក្រុមសង្គមស៊ីវិល និងអ្នកតំណាងនៃសហគមន៍អ្នកផ្ដល់ជំនួយ ។

សរុបមក ការស្រាវជ្រាវនេះ ធ្វើឡើងចំពេលដ៏សំខាន់ដែលរដ្ឋកំពុងធ្វើការផ្លាស់ប្ដូរសេដ្ឋកិច្ច[៣] ។ របកគំហើញនៃការស្រាវជ្រាវ នឹងជួយពន្យល់ថា តើរដ្ឋកម្ពុជាកំពុងធ្វើដំណើរចំលើមាគ៌ាអភិវឌ្ឍន៍ដ៏ត្រឹមត្រូវឬទេ ហើយបើសិនមិនត្រឹមត្រូវទេ តើតួអង្គពាក់ព័ន្ធនានាគួរមានប្រតិកម្មបែបណា ដើម្បីរុញច្រានរដ្ឋឱ្យចូលទៅក្នុងមាគ៌ាដែលគួរដើរតាមនោះវិញ ។

(*សូមមើលឯកសារយោងនៅក្នុងអត្ថបទជាភាសាអង់គ្លេស*)

**កំណើនគួបផ្សំគ្នានៃវិស័យកសិកម្ម ឧស្សាហកម្ម (ជាពិសេសផ្នែកកាត់ដេរ) និងទេសចរណ៍ គឺជាកំលាំងដ៏សំខាន់ជំរុញកំណើនសេដ្ឋកិច្ច ។**

**ការរក្សាសន្តិភាព និងសណ្ដាប់ធ្នាប់សង្គម គឺជាលក្ខខណ្ឌត្រូវមានជាមុនសម្រាប់ការលូតលាស់សេដ្ឋកិច្ច ។**

៣ Hughes and Un (បោះពុម្ពផ្សាយក្នុងពេលខាងមុខ) បានលើកឡើងថា កម្ពុជាបានងើបផុតពីសម័យក្រោយជម្លោះ និងឈានចូលទៅក្នុងដំណាក់កាលថ្មីនៃការផ្លាស់ប្ដូរសេដ្ឋកិច្ច ។ ម្យ៉ាងទៀត កម្ពុជាបានធ្វើសមាហរណកម្មចូលទៅក្នុងតំបន់ និងសាកលលោក ។ នៅមុនពេលមានការធ្លាក់ចុះសេដ្ឋកិច្ចសាកល កម្ពុជាមានកំណើនសេដ្ឋកិច្ចជាមធ្យម ៨,៧%ក្នុងមួយឆ្នាំនៅអំឡុងឆ្នាំ១៩៩៦ ដល់ ២០០៦ ហើយមានសេដ្ឋកិច្ចធ្លាក់ចុះ ដោយសារវិបត្តិហិរញ្ញវត្ថុ ។ ទោះជាយ៉ាងនេះក្ដី វិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ១៩៩៧ សឹងមិនមានផលប៉ះពាល់ដល់កម្ពុជាឡើយ ។